អំបិលគឺជាសារធាតុរក្សាទុកដ៏មានប្រសិទ្ធភាព

លក្ខណៈសំខាន់មួយទៀតរបស់អំបិល គឺវាជាសារធាតុរក្សាទុក។ មុនសម័យមានទូទឹកកក នៅពេលមនុស្សធ្វើដំណើរឆ្ងាយ ហើយចង់រក្សាសាច់កុំឲ្យខូច ពួកគេតែងតែប្រឡាក់សាច់ដោយអំបិល។ អំបិលមានប្រសិទ្ធភាព ក្នុងការទប់ស្កាត់កម្លាំងនៃការពុករលួយ ដែលបើគ្មានវាទេ សាច់នោះនឹងខូចយ៉ាងឆាប់រហ័ស។

ដូចគ្នានេះដែរ ដោយសារយើងជាអំបិលនៃផែនដី យើងត្រូវបានដាក់នៅទីនេះ ដើម្បីទប់ស្កាត់កម្លាំងនៃការពុករលួយ។ ដរាបណាយើងនៅលើផែនដីនេះ កម្លាំងនៃអំពើអាក្រក់ដែលកំពុងធ្វើសកម្មភាពដូចជា ការមិនគោរពព្រះ ការបះបោរប្រឆាំងនឹងព្រះ និងអំពើអាក្រក់ផ្សេងៗទៀត នឹងមិនត្រូវបានអនុញ្ញាត ឲ្យឈានដល់កម្រិតពេញលេញរបស់វាឡើយ។

លុះត្រាតែពួកជំនុំ ត្រូវបានដកចេញពីផែនដីសិន ទើបអំពើទុច្ចរិតនឹងឈានដល់ចំណុចកំពូល ចុងក្រោយរបស់វា។ យើងនៅទីនេះ ដើម្បីរារាំង និងទប់ស្កាត់កម្លាំងនៃការពុករលួយទាំងនោះ មិនថាវាកំពុងប៉ះពាល់ដល់ផ្នែកសីលធម៌ សង្គម នយោបាយ ឬផ្នែកណាមួយផ្សេងទៀតនៃសង្គមដែលយើងរស់នៅនោះឡើយ។ យើងមានការទទួលខុសត្រូវក្នុងការទប់ស្កាត់កម្លាំងទាំងនោះ ពីព្រោះយើងគឺជា អំបិលនៃផែនដី។

ឱកាសមួយដើម្បីឆ្លើយតប

ខ្ញុំជឿជាក់យ៉ាងមុតមាំថា ពួកជំនុំនៃព្រះយេស៊ូវគ្រីស្ទ នៅគ្រប់ទីកន្លែងលើពិភពលោក អាចក្រោកឈរឡើងដើម្បីឆ្លើយតបនឹងស្ថានការណ៍នេះ និងបំពេញតាមលក្ខខណ្ឌដ៏សាមញ្ញ ច្បាស់លាស់ និងជាក់លាក់ដែលព្រះជាម្ចាស់បានដាក់ឲ្យ។ ប្រសិនបើយើងធ្វើដូច្នោះបាន យើងអាចផ្លាស់ប្តូរហើយទប់ស្កាត់ដំណើរឆ្ពាក់ចុះនៃព្រឹត្តិការណ៍ទាំងឡាយដែលកំពុងកើតឡើង។ ផ្ទុយទៅវិញ ប្រសិនបើយើងមិនធ្វើដូច្នោះទេ នោះវានឹងជាកំហុសរបស់យើង ហើយយើងនឹងជាអ្នកដែលរងទុក្ខមុនគេ និងខ្លាំងជាងគេផងដែរ។ ប្រសិនបើយើងរងទុក្ខដោយសារការបរាជ័យរបស់យើងក្នុងការបំពេញតាមលក្ខខណ្ឌរបស់ព្រះជាម្ចាស់ នោះយើងសមនឹងទទួលលទ្ធផលនោះហើយ។ មុននឹងបន្តទៅមុខទៀត សូមអនុញ្ញាតឲ្យខ្ញុំលើកយកការអនុវត្តដ៏សាមញ្ញមួយ ពីអ្វីដែលយើងបានសិក្សារហូតមកដល់ពេលនេះ។ ប្រសិនបើអ្នកមិនជឿជាក់លើអ្វីដែលខ្ញុំបានបង្ហាញទេ នោះសូមកុំមានអារម្មណ៍ថាត្រូវបង្ខំឲ្យឆ្លើយតបឡើយ។ ប៉ុន្តែ ប្រសិនបើអ្នកជឿថា អ្វីដែលខ្ញុំបានពន្យល់យ៉ាងជាក់ស្តែងនេះ គឺជាសេចក្តីបង្រៀនរបស់ព្រះគម្ពីរនោះខ្ញុំសូមអញ្ជើញអ្នកឲ្យអាន ម៉ាថាយ 5:13 ម្តងទៀត៖

អ្នករាល់គ្នាជាអំបិលនៃផែនដី បើអំបិលបាត់ជាតិប្រៃហើយ នោះតើនឹងយកអ្វី ដើម្បីធ្វើឲ្យប្រៃឡើងវិញបាន ជារបស់គ្មានប្រយោជន៍ទៀតសោះ មានតែបោះបង់ចោលទៅក្រៅ ឲ្យមនុស្សដើរជាន់ប៉ុណ្ណោះ។

ឥឡូវនេះ ខ្ញុំចង់ឲ្យខនេះមានន័យផ្ទាល់ខ្លួនសម្រាប់អ្នក ដើម្បីឲ្យអ្នកអាចយកព្រះបន្ទូលរបស់ព្រះយេស៊ូវ មកអនុវត្តក្នុងជីវិតរបស់អ្នក។ យើងដឹងថា ព្រះយេស៊ូវកំពុងមានបន្ទូលទៅកាន់គ្រីស្ទបរិស័ទ ហើយយើងក៏ជាគ្រីស្ទបរិស័ទដែរ។ ដូច្នេះ នៅកន្លែងដែលមានពាក្យថា "អ្នករាល់គ្នា" ខ្ញុំចង់ឲ្យអ្នកអានថា "យើង" ។ ហើយនៅកណ្តាលខនេះ ដែលមានពាក្យថា "ជារបស់គ្មានប្រយោជន៍ទៀតសោះ" ខ្ញុំចង់ឲ្យអ្នកអានថា "យើងគ្មានប្រយោជន៍ទៀតសោះ" ។ ខ្ញុំជឿថា ការកែប្រែបែបនេះគឺសមរម្យទាំងស្រុង។

បន្ទាប់ពីអ្នកបាននិយាយពាក្យខាងក្រោមនេះហើយ អ្នកនឹងត្រូវទទួលខុសត្រូវ នៅចំពោះព្រះជាម្ចាស់ ទាំងក្នុងពេលបច្ចុប្បន្ន និងក្នុងភាពអស់កល្បជានិច្ច ចំពោះអ្វីដែលអ្នកបាននិយាយ។ ដូច្នេះ ប្រសិនបើអ្នកបានត្រៀមខ្លួនហើយ សូមសាកល្បងអានវាឮៗឥឡូវនេះ៖

យើងជាអំបិលនៃផែនដី បើអំបិលបាត់ជាតិប្រៃហើយ នោះតើនឹងយកអ្វី ដើម្បីធ្វើឲ្យប្រៃឡើងវិញបាន យើងគ្មានប្រយោជន៍ទៀតសោះ មានតែបោះបង់ចោលទៅក្រៅ ឲ្យមនុស្សដើរជាន់ប៉ុណ្ណោះ។

ស្វែងយល់ពីព្រះបន្ទូលព្រះឲ្យកាន់តែស៊ីជម្រៅ

សម្រាប់ការបង្រៀនបន្ថែមអំពីប្រធានបទនេះ សូមចូលទៅកាន់គេហទំព័ររបស់យើង៖
www.derekprince.com/km-kh/resources

ស្កេន QR ដើម្បីចូលគេហទំព័រ DPM-KH

ព័ន្ធកិច្ច ដេរេក ព្រីនស៍ កម្ពុជា
Facebook / Youtube: Derek Prince Ministries Cambodia | www.derekprince.com/km-kh



ISSUE #096

លោកដេរេក ព្រីនស៍៖ សេចក្តីបង្រៀនជាលិខិត

ការយល់ដឹងពីព្រះគម្ពីរ ដើម្បីផ្លាស់ប្រែជីវិតរបស់អ្នក

Free COPY

ការរស់នៅជាអំបិល និងពន្លឺ

ផ្នែកទី ២៖ យើងគឺជាអំបិល

នៅក្នុងកេរដំណែលនៃសេចក្តីបង្រៀនចំនួនបីផ្នែក ដែលផ្អែកលើសៀវភៅរបស់លោក ដេរេក ព្រីនស៍ មានចំណងជើងថា ការរស់នៅជាអំបិល និងជាពន្លឺ យើងកំពុងសិក្សាអំពីប្រធានបទស្តីពីតួនាទី និងការទទួលខុសត្រូវរបស់យើងជាគ្រីស្ទបរិស័ទ ចំពោះប្រជាជាតិដែលយើងរស់នៅ។

នៅក្នុងលិខិតមុន យើងបានណែនាំអំពីការពិពណ៌នារបស់ព្រះយេស៊ូវអំពីពួកជំនុំ ដែលទ្រង់បានមានបន្ទូលនៅក្នុងសារមួយដែលគេស្គាល់ថា សេចក្តីអធិប្បាយលើភ្នំ ដូចបានកត់ត្រានៅក្នុងគម្ពីរ ម៉ាថាយ 5:13–14។ យើងគឺជា "ទីក្រុងដែលនៅលើភ្នំ" ដែលភ្នែករបស់មនុស្សលោកកំពុងតែសម្លឹងមើលយ៉ាងយកចិត្តទុកដាក់។ យើងក៏ជា "ពន្លឺ" ផងដែរ គឺជាពន្លឺតែមួយគត់ដែលបង្ហាញព្រះគ្រីស្ទដល់ពិភពលោកដែលកំពុងវិនាស។

នៅក្នុងលិខិតនេះ យើងនឹងផ្តោតទៅលើតួនាទីទីបីរបស់យើង៖ យើងគឺជា "អំបិលនៃផែនដី"។ ម្តងទៀត ពាក្យ "the" នៅទីនេះមានន័យថាមានតែមួយគត់។ វាមានន័យថាផែនដីនេះគ្មានអំបិលផ្សេងទៀតឡើយ យើងគឺជាអំបិលតែមួយគត់ដែលមានសម្រាប់ផែនដី។ មានវិធីជាច្រើនដែលយើងអាចយកន័យសំខាន់របស់អំបិលមកអនុវត្តបាន។ ទោះជាយ៉ាងណា ដោយសារខ្ញុំមិនមែនជាអ្នកវិទ្យាសាស្ត្រ ខ្ញុំនឹងពន្យល់ក្នុងកម្រិតដ៏សាមញ្ញបំផុត។ ខ្ញុំគ្រាន់តែចង់លើកឡើងអំពីការពិតជាក់ស្តែងមួយចំនួន ដែលយើងអាចសង្កេតឃើញបានយ៉ាងងាយស្រួលអំពីអំបិល។

អំបិលផ្តល់រសជាតិ

មុខងារដ៏សំខាន់មួយរបស់អំបិល គឺផ្តល់រសជាតិដល់អ្វីដែលគ្មានរសជាតិ។ នៅក្នុងគម្ពីរ យ៉ូប 6:6 លោកយ៉ូប បាននិយាយថា៖ *"ឯរបស់ដែលគ្មានរសជាតិ តើនឹងបរិភោគឥតអំបិលបានឬទេ តើសរបស់ពងមានរសឬទេ"* ចម្លើយគឺ មិនមានឡើយ។ ហេតុនេះហើយបានជា នៅពេលអ្នកបរិភោគផ្នែកសនៃស៊ុត ប្រសិនបើអ្នកដូចជាខ្ញុំ អ្នកនឹងរោយអំបិលបន្តិចលើវា ដើម្បីឲ្យវាមានរសជាតិ។

ដូចគ្នានេះដែរគ្រីស្ទបរិស័ទគឺជា "អំបិលនៃផែនដី" ។ យើងមានវត្តមាននៅទីនេះ ដើម្បីផ្តល់រសជាតិដល់ផែនដីនេះនៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់។ បើគ្មានវត្តមានរបស់យើងនៅលើផែនដីទេ នោះគ្មានហេតុផលអ្វីដែលព្រះជាម្ចាស់ត្រូវបន្តប្រព្រឹត្តចំពោះពិភពលោកនេះដោយព្រះគុណ និងសេចក្តីមេត្តាករុណាទៀតឡើយ។ យើងគឺជាកត្តាតែមួយគត់ដែលធ្វើឲ្យផែនដីនេះ អាចទទួលយកបាននៅចំពោះព្រះភក្ត្រទ្រង់ ហើយក៏ជាអ្នកទប់ស្កាត់តែមួយគត់ដែលរារាំងការជំនុំជម្រះ និងសេចក្តីក្រោធចុងក្រោយរបស់ទ្រង់មិនឲ្យធ្លាក់មកលើពិភពលោក ដែលបដិសេធព្រះគ្រីស្ទ។ ដរាបណាយើងនៅលើផែនដីនេះ ការទទួលខុសត្រូវរបស់យើង គឺរស់នៅក្នុងរបៀបមួយ ដែលធ្វើឲ្យផែនដីនេះ គួរឲ្យទទួលយកបាននៅចំពោះព្រះជាម្ចាស់។

ដោយសារអំបិលតែងប៉ប្រាប់

នៅក្នុងគម្ពីរ លោកុប្បត្តិ ១៨ យើងអានអំពីពេលដែលព្រះអម្ចាស់ បានស្នាក់នៅផ្ទះរបស់អ័ប្រាហាំ ខណៈពេលដែលទ្រង់កំពុងធ្វើដំណើរ ទៅកាន់ក្រុងសូដុំម។ ព្រះអម្ចាស់បានប្រាប់អ័ប្រាហាំអំពីផែនការរបស់ទ្រង់ គឺទ្រង់បានយាងមកដើម្បីនាំការជំនុំជម្រះមកលើទីក្រុងនោះ។ អ័ប្រាហាំ មានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះអ្វីដែលព្រះបានមានបន្ទូល ពីព្រោះក្មួយប្រុសរបស់គាត់ គឺលោកឡុត និងគ្រួសាររបស់លោកឡុត រស់នៅក្នុងក្រុងសូដុំម។ ដូច្នេះ អ័ប្រាហាំបានដើរជាមួយព្រះអម្ចាស់ទៅកាន់ទិសដៅនៃក្រុងសូដុំម ហើយបានទូលអង្វរយ៉ាងក្លាហាន សូមឲ្យទ្រង់មេត្តាទុកជីវិតដល់ទីក្រុងដ៏អាក្រក់នោះ។ បើនិយាយម្យ៉ាងទៀត គាត់បាន «ចរចា» ជាមួយព្រះអម្ចាស់ (ប្រសិនបើខ្ញុំអាចប្រើពាក្យនេះបាន) ដោយផ្អែកលើចំនួនមនុស្សសុចរិត ដោយទូលថា៖ "ព្រះអង្គម្ចាស់ ប្រសិនបើមានមនុស្សសុចរិតចំនួន៥០នាក់នៅក្នុងទីក្រុងនោះ តើព្រះអង្គនឹងរក្សាទុកទីក្រុងនោះឬទេ?" ព្រះអម្ចាស់បានឆ្លើយថា "បាទ" ។

បន្ទាប់មកលោកអ័ប្រាហាំទូលថា៖ "ប្រសិនបើមានមនុស្សសុចរិតត្រឹមតែ៤០នាក់ តើព្រះអង្គនឹងប្រណីដល់ទីក្រុងនេះឬទេ?" ព្រះអម្ចាស់មានបន្ទូលថា៖ "បាទ" ។

លោកអ័ប្រាហាំទូលបន្តថា៖ "ប្រសិនបើមានមនុស្សសុចរិតត្រឹមតែ៣០នាក់ តើព្រះអង្គនឹងប្រណីដល់ទីក្រុងនេះឬទេ?" ព្រះអម្ចាស់មានបន្ទូលថា៖ "បាទ" ។

លោកអ័ប្រាហាំ ទូលបន្តថា៖ "ប្រសិនបើមានមនុស្សសុចរិតត្រឹមតែ២០នាក់ តើព្រះអង្គនឹងប្រណីដល់ទីក្រុងនេះឬទេ?" ព្រះអម្ចាស់មានបន្ទូលថា៖ "បាទ"។

ទីបំផុត អ័ប្រាហាំទូលថា៖ "សូមកុំឲ្យព្រះអម្ចាស់ខ្ញាល់ឡើយ ទូលបង្គំនឹងទូលតែម្តងនេះទៀតថា នៅទីនោះប្រហែលជារកបានតែ១០នាក់ទេ។ តើព្រះអង្គនឹងប្រណីដល់ទីក្រុងនេះ ដោយយល់ដល់មនុស្សសុរិត១០នាក់នេះឬទេ?" ព្រះអម្ចាស់មានបន្ទូលថា៖ "បាទ យើងនឹងមិនបំផ្លាញទេ" ។ ប៉ុន្តែ សោកនាដកម្មគឺថា ព្រះអម្ចាស់មិនបានរកឃើញមនុស្សសុចរិត១០នាក់នៅក្នុងក្រុងសូដុំមឡើយ។

រាល់ពេលដែលខ្ញុំអានរឿងនេះ ខ្ញុំមិនអាចជៀសផុតពីការឆ្ងល់បានទេថា ប្រហែលជាអ័ប្រាហាំបានគិតគណនាបន្តិចនៅក្នុងចិត្ត។ ប្រហែលជាគាត់បានគិតថា៖ *"នៅទីនោះមានក្មួយប្រុសរបស់ខ្ញុំ មានប្រពន្ធរបស់គាត់ មានកូនស្រីដែលមិនទាន់រៀបការ ហើយក៏មានកូនស្រីដែលបានរៀបការរួច... បូកសរុបទៅពួកគេគួរតែអាចរកបានមនុស្សសុចរិត១០នាក់មិនខានទេ!"* ហើយបើ លោកឡុត បានបំពេញតួនាទីរបស់គាត់ដូចដែលគួរធ្វើ ពួកគេប្រហែលជាអាចមានចំនួនលើសពីនេះផង។ ប៉ុន្តែ លោកឡុត គឺជាអ្នកជឿម្នាក់ដែលបានបរាជ័យចំពោះព្រះជាម្ចាស់។ មែនហើយ គាត់ជាអ្នកជឿពិតប្រាកដ។ គាត់បានឮការបើកសម្តែងទាំងឡាយ ដែលព្រះបានប្រទានដល់អ័ប្រាហាំ។ ប៉ុន្តែ គាត់មិនបានរស់នៅស្របតាមពន្លឺនៃការបើកសម្តែងដែលគាត់បានទទួលនោះទេ។

វត្តមានរបស់យើងធ្វើឲ្យមានភាពខុសប្លែក

យើងអាចរៀនបាននូវគោលការណ៍អស់កល្បជានិច្ចមួយពីគំរូរបស់លោកឡុត។ ដោយសារមនុស្សសុចរិតតែ១០នាក់ប៉ុណ្ណោះ ព្រះជាម្ចាស់សុខចិត្តទុកជីវិតឲ្យទីក្រុងមួយទាំងមូល។ សមាមាត្រនេះ ក៏អាចអនុវត្តបានសម្រាប់សព្វថ្ងៃនេះដែរ។ អំបិលត្រឹមតែ១០គ្រាប់ អាចមានតម្លៃចារសម្រាប់មនុស្សជាច្រើននៅចំពោះព្រះជាម្ចាស់។ ដូចដែលខ្ញុំបាននិយាយរួចមកហើយ ការទទួលខុសត្រូវរបស់យើង គឺត្រូវរស់នៅក្នុងរបៀបមួយដែលធ្វើឲ្យផែនដីនេះ គួរឲ្យទទួលយកបាននៅចំពោះព្រះជាម្ចាស់។ វត្តមានរបស់យើងធ្វើឲ្យមានភាពខុសប្លែក។ វត្តមានរបស់យើងធ្វើឲ្យព្រះជាម្ចាស់ប្រព្រឹត្តចំពោះពិភពលោកនេះ ក្នុងរបៀបមួយដែល បើគ្មានយើង ទ្រង់នឹងមិនប្រព្រឹត្តដូច្នោះឡើយ។ អ្នកជឿគ្រប់រូបគួរតែជាអំបិលមួយគ្រាប់នៅក្នុងកន្លែងជាក់លាក់ដែលព្រះជាម្ចាស់ បានដាក់ពួកគេឲ្យនៅ។ ព្រះជាម្ចាស់មិនបានប្រមូលអ្នកជឿទាំងអស់ ឲ្យនៅកន្លែងតែមួយឡើយ ដូចជាយើងក៏មិនដាក់អំបិលទាំងអស់ដែលយើងត្រូវប្រើសម្រាប់អាហារមួយពេល ទៅក្នុងមាត់តែមួយពេលដែរ។ បើធ្វើដូច្នោះ វានឹងប្រៃខ្លាំងពេក! យើងម្នាក់ៗត្រូវបានព្រះជាម្ចាស់បញ្ជូនឲ្យទៅនៅកន្លែងផ្សេងៗគ្នា ដើម្បីធ្វើជាអំបិលផ្តល់រសជាតិដល់ពិភពលោក មិនថានៅក្នុងគ្រួសាររបស់អ្នក នៅសាលារៀនរបស់អ្នក នៅកន្លែងការងាររបស់អ្នក ឬនៅទីកន្លែងណាផ្សេងទៀតឡើយ។ អ្នកប្រហែលជានិយាយថា "ខ្ញុំមានអារម្មណ៍ឯកោណាស់នៅទីនោះ" ។ ប៉ុន្តែ អ្នកនៅទីនោះដោយមានគោលបំណងមួយ។ អ្នកនៅទីនោះ ដើម្បីផ្តល់រសជាតិដល់កន្លែងមួយនោះ។ បើគ្មានអ្នកទេ កន្លែងនោះនឹងគ្មានរសជាតិអ្វីសោះ។

ក្នុងនាមជាគ្រីស្ទបរិស័ទ យើងប្រៀបដូចជាគ្រាប់អំបិល។ វត្តមានរបស់យើងធ្វើឲ្យមានភាពខុសប្លែក។ មិនគួរមានអ្នកជឿណាម្នាក់ក្នុងចំណោមយើង ដែលវត្តមានរបស់គាត់មិនធ្វើឲ្យមានភាពខុសប្លែកនោះឡើយ។

